# ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ អញ្ជើញជាអធិបតីក្នុងពិធីបើកការប្រកួតជ្រើសរើសក្រុមយុវជន បង្កើតអាជីវកម្មថ្មី"ពន្លកសហគ្រិន" នៅសណ្ឋាគារកាំបូឌីយ៉ាណា



ពិធីបើកការប្រកួតជ្រើសរើសក្រុមយុវជនបង្កើតអាជីវកម្មថ្មី"ពន្លកសហគ្រិន" ដែលរៀបចំឡើងដោយសមាគមភ្នំពេញក្លឹប (PPC) ត្រូវបាន ប្រារព្ធធ្វើឡើង នៅរសៀលថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ២០១៤ ក្រោមអធិបតីភាព ឯកឧត្តម **ចម ប្រសិទ្ធ** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅសណ្ឋាគារកាំបូឌីយ៉ាណា រាជធានីភ្នំពេញ ។

លោកឧកញ៉ាបណ្ឌិត **ឡឹក បូផា** ប្រធានក្លឹបភ្នំពេញ បានបញ្ជាក់ថាៈ ការប្រារព្ធពិធីនេះ គឺជាការជម្រុញលើកទឹកចិត្តដល់យុវជនកម្ពុជា ដែលបច្ចុប្បន្នមានចំនួនប្រមាណ៣លាននាក់ ឱ្យមានការយល់ដឹងឱ្យកាន់តែទូលំទូលាយ និងចូលរួមវិស័យសហគ្រិនឱ្យបានខ្លាំងក្លា ព្រោះវិស័យនេះ ជួយយុវជនកម្ពុជាឱ្យមានឱកាស និងលទ្ធភាពបង្កើតការងារខ្លួនឯងផង និងយុវជនដ៏ទៃទៀតផង ។

លោកឧកញ៉ា បានបញ្ជាក់ថាៈ ដើម្បីទទួលបានជ័យលាភី ត្រូវឆ្លងកាត់ការប្រលងជា០៤ដំណាក់កាល គឺ**ទី១ៈ**ការចម្រាញ់ឯកសារសុំចូលប្រកួត **ទី២ៈ**ការគាំទ្រគំនិតអាជីវកម្មពីគណៈកម្មការ និងមហាជន **ទី៣ៈ**ការប្រកួតសមាសភាពរួម និង **ទី៤ៈ**កាជ្រើសរើសជ័យលាភីបេក្ខជនពីលេខ ១ ដល់លេខ៣ ។

ស្ថិតក្នុងឱកាសនោះ អង្គពិធីក៏មានកិត្តិយសផងដែរ ដែលលោក ម៉ូរីតា អតីតៈអគ្គនាយកធនាគារអភិវឌ្ឍន៏អាស៊ី (ADB) បានចូលរួមធ្វើបទអន្តរាគមន៏ ដោយបានរំលឹកឡើងវិញពីការចូលរួមរបស់លោក ជាមួយរាជរដ្ឋាភិបាលកម្ពុជា ដឹកនាំដោយ**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** បន្ទាប់ពីកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ដើម្បីរួមចំណែកការកសាង និងអភិវឌ្ឍន៏កម្ពុជា ឡើងវិញ ។


06 June 2014


០៦ ខែមិថុនា ឆ្នាំ២០១៤
រៀបចំដោយ Organized By
Under the High Presidency of His
Senior Minister and Minister of
Phnom Penh, 06




បន្ទាប់មកអង្គពិធីបានតាមដានទស្សនា ការចាក់វីដេអូរក្លីប ស្តីពីសកម្មភាពរបស់យុវជនបង្កើតអាជីវកម្មថ្មី **"ពន្លក សហគ្រិន"** លើគម្រោងអាជីវកម្មរបស់គេនីមួយៗ និងបន្ទាប់មកតំណាងសហគ្រិនវ័យក្មេង ដែលជាបេក្ខភាពប្រកួតប្រជែង ចំនួន១៧ ក្រុម បានឡើងលើវេទិការ ដើម្បីធ្វើបទបង្ហាញខ្លីៗពីគម្រោងអាជីវកម្មរបស់ខ្លួន និងសំណូមពរសុំជំនួយឧបត្ថម្ភ ផងដែរ ។

លោក **គីម អឿន** នាយកកិច្ចសហប្រតិបត្តិការកម្ពុជា-ជប៉ុន (CJCC) បានបញ្ជាក់ថាៈ ការរៀបចំកម្មវិធីនេះឡើង ជាការរួមចំណែក និងលើកកំពស់វិស័យសហគ្រាសធុនតូច និងមធ្យមនៅកម្ពុជា ហើយក៏ជាការផ្តល់ឱកាស និងលើកទឹកចិត្ត ដល់យុវជនកម្ពុជា មានលទ្ធភាពបង្កើតអាជីវកម្មដោយខ្លួនឯង ដល់អ្នកដ៏ទៃ និងសង្គម ។ ជាមួយគ្នានេះ លោកក៏បាន ធ្វើការកោតសរសើដល់លោកស្រី **មិត្ត លក្ខិណា** ជាសហគ្រិនស្ត្រីខ្មែរ ដែលបានលះបង់ពេលវេលា និងកំលាំងកាយចិត្ត ក្នុងការ ជួយគៀងគរការគាំទ្រ លើកម្មវិធីនេះ ពីដៃគូរមួយចំនួន ដូចជាៈមកពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងវិស័យឯកជននានា ។

បន្ទាប់ពីឯកឧត្តម ទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** បានអញ្ជើញប្រគល់បាច់ផ្កាដល់លោកស្រី **មិត្ត លក្ខិណា** ជាការ ថ្លែងអំណរគុណ និងលើកទឹកចិត្ត រួចមក ឯកឧត្តម **សួស យ៉ារ៉ា** អនុប្រធានគណៈកម្មាធិការទី៥ នៃរដ្ឋសភាជាតិ អ្នកតំណាងរាស្ត្រមណ្ឌលខេត្តព្រះវិហារ និងជា សមាជិកក្លឹបភ្នំពេញ បានឡើងធ្វើចំណាប់អារម្មណ៍ ដោយធ្វើការកោត សរសើរពីគម្រោងបង្កើតអាជីវកម្មថ្មី នៃក្រុមប្រកួតប្រជែងទាំង១៧ក្រុម ដែលមានកម្មវត្ថុអាជីវកម្មខុសៗគ្នា ក្នុងគំនិត ច្នៃប្រឌិតរស់រវើក ។ ជាមួយគ្នានេះឯកឧត្តម ក៏បានបង្ហាញពីមោទនៈភាព ដែលកម្មវិធីនេះ ត្រូវបានចូលរួមពីឯកឧត្តម ទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** ដែលឯកឧត្តម ជាឥស្សរៈជនដ៏មានបទពិសោធន៍ ក្នុងវិស័យសេដ្ឋកិច្ច និងពាណិជ្ជកម្មជាតិ-អន្តរជាតិ ក៏ដូចជាអាជីវកម្មក្នុងស្រុកផងដែរ ។






មានប្រសាសន៍នាឱកាសនោះ ឯកឧត្តម ទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា និងក្នុងនាម ឯកឧត្តមផ្ទាល់ ឯកឧត្តម បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះសមាគមភ្នំពេញក្លឹប និងដៃគូឧបត្ថម្ភទាំងអស់ ដែលបានរៀបចំកម្មវិធីប្រកួតជ្រើសរើសក្រុមយុវជនបង្កើតអាជីវកម្មថ្មីប្លែក ដែលមានឈ្មោះហៅថាៈពន្លកសហគ្រិននេះឡើង ដើម្បីផ្តល់ឱកាសឱ្យយុវជនចូលរួមអភិវឌ្ឍន៍ចំណេះជំនាញរបស់ពួកគេ និងក៏ដូចជាចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ចសង្គម ។

ឯកឧត្តម បានធ្វើការកោតសរសើរ ចំពោះគំនិតអាជីវកម្មរបស់ក្រុមប្រកួតប្រជែងទាំង១៧ ខាងលើ តែឯកឧត្តម បានផ្តល់ទស្សនៈ ក្នុងន័យតម្រែតម្រង់ទិសដោយបានដាក់ជាសំណួរថាៈបើមានការឧបត្ថម្ភពីស្ថាប័ន រឺពីសប្បុរសជននានាលើគម្រោងអាជីវកម្មនោះហើយ តើអាជីវកម្មនោះ អាចរស់ដោយខ្លួនឯងទៅមុខទៀតបានដែររឺទេ? រឺក៏យើងត្រូវការ

ជំនួយឧបត្ថម្ភរហូត ? ចំលើយពិតជាមិនអាចទេ ជំនួយបានត្រឹមតែកំរិតណាមួយប៉ុណ្ណោះ ។ ដូច្នេះ ដើម្បីបង្កើតអាជីវកម្មមានភាពជោគជ័យបាន ឯកឧត្តម បានផ្តល់នូវគំនិតអាជីវកម្មមួយចំនួនមានដូចជាៈ អាជីវកម្មរបស់ខ្លួនត្រូវគោលដៅច្បាស់លាស់ - មានទស្សនៈវិស័យវែងឆ្ងាយទៅមុខ-មានភាពរស់រវើកផ្នែកឆ្នៃប្រឌិត-មានការគ្រប់គ្រងល្អប្រសើរ-ផលិតផលត្រូវមានកំរិតស្តង់ដា និងរក្សាឱ្យមានចិរភាព ជាពិសេសទៅទៀតគម្រោងអាជីវកម្មគួរប្រកាន់ខ្ជាប់នូវគោលការណ៏ ស ៥ គឺៈ សម្រិតសម្រាំង សណ្តាប់ធ្នាប់ សម្អាត ស្តង់ដា និងស្ថិតស្ថេរ ដែលជាវិធីសាស្រ្តដ៏មានអត្ថប្រយោជន៍ដ៏សំខាន់ និងជាមូលដ្ឋានគ្រឹះដំបូង ឆ្ពោះទៅចាប់យកស្តង់ដាឈានមុខមួយចំនួនទៀតដូចជា GMP,ISO9001 ជាដើម។ ជាពិសេសទៅទៀតនោះ បើគម្រោងផែនការអាជីវកម្មល្អ គឺនឹងអាចមានក្រុមហ៊ុន រឺអ្នកមានធនធាន ទិញបច្ចេកវិទ្យា រឺសហការរួមអាជីវកម្ម ក៏អាចថាបាន។ ជាមួយគ្នានេះ ឯកឧត្តម ទេសរដ្ឋមន្រ្តី **ចម ប្រសិទ្ធ** បានលើកឡើងពីបរិបទនៃ ការប្រកួតប្រជែងអាជីវកម្មនាពេលបច្ចុប្បន្ន ជាពិសេសក្នុងក្របខ័ណ្ឌអាស៊ាន ដែលសហគមន៏សេដ្ឋកិច្ចមួយនឹងបង្កើតឡើងនាចុងឆ្នាំ ២០១៥ ខាងមុខ ។ ពេលនោះគឺនឹងមានលំហូរដោយសេរី នូវទំនិញ ពីប្រទេសមួយទៅប្រទេសមួយ។ ដូច្នេះ ការទាញយកឧត្តមភាពប្រកួតប្រជែងគឺមានលក្ខណៈស្រួចស្រាវណាស់ ។ ពីព្រោះវាទាក់ទងនិងគុណភាព សោភ័ណ្ឌភាព កំរិតស្តង់ដា និងតម្លៃសមរម្យនៃផលិតផលផងដែរ ។

ឯកឧត្តម ទេសរដ្ឋមន្រ្តី **ចម ប្រសិទ្ធ** បានលើកឡើងពីការខិតខំរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការធ្វើសមាហរណកម្មសេដ្ឋកិច្ច ពាណិជ្ជកម្ម ក្នុងប្រព័ន្ធពិភពលោក ។ កត្តានេះ ធ្វើឱ្យកម្ពុជាចរចារបាន នូវការទំលាក់ពន្ធគយស្ទើរតែ 0%ទាំងអស់នូវរាល់មុខទំនិញនាំចេញ ។ ក៏ប៉ុន្តែ អ្វីដែលជាភាពប្រឈម គឺបញ្ហារបាំង មិនមែនពន្ធគយ ដែលទាក់ទងនិងកត្តាអនាម័យ និងភូតគាមអនាម័យ និងកំរិតស្តង់ដានៃមុខទំនិញរឺផលិតផល ។

ដើម្បីចូលរួមលើកស្ទួយកម្មវិធីប្រកួតប្រជែងនេះ ឯកឧត្តម ទេសរដ្ឋមន្រ្តី **ចម ប្រសិទ្ធ** បានឧបត្ថម្ភទឹកប្រាក់ចំនួន ១ពាន់ដុល្លាអមេរិក ព្រមទាំងជូនពរ និងសង្ឃឹមថាៈកម្ពុជានឹងមានសហគ្រិនវ័យក្មេងកាន់តែច្រើន ជាពិសេសមកពីប្រភពនិស្សិត ដែលពោរពេញដោយចំណេះដឹងក្នុងគ្រឹះស្ថានសិក្សារបស់ខ្លួន ។


Opening Ceremony
Young Entrepreneur Venture Contest
"Young Entrepreneur"
Senior Minister and Minister of Industry and Handicraft
Organized By


Opening Ceremony
Young Entrepreneur Venture Contest
"Young Entrepreneur"
Under the High Presidency of His Excellency Cham Prasidh
Senior Minister and Minister of Industry and Handicraft
Organized By





